ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.....០២៧ អបស.មព...........

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៩

# គោលនយោបាយជាតិស្តីពីការគ្រប់គ្រងសំណល់ ពីសេវាថែទាំសុខភាពនៅព្រះរាជាណាចក្រកម្ពុជា

## សេចក្តីផ្តើម

សកម្មភាពភាគច្រើន ដែលទាក់ទងនឹងការថែទាំសុខភាព បណ្តាលឱ្យមានការកើតជាសំណល់ដែលអាចបង្កឱ្យមានជាពិការភាព និង មរណភាព ទោះបីជាសំណល់វេជ្ជសាស្ត្រមួយផ្នែកធំមានលក្ខណៈប្រហាក់ប្រហែលសំណល់រឹងតាមលំនៅដ្ឋានក៏ដោយ សំណល់វេជ្ជសាស្ត្រមួយចំនួន ត្រូវតែរៀបចំទុកដាក់ និងគ្រប់គ្រងត្រឹមត្រូវដើម្បីកាត់បន្ថយ រឺលប់បំបាត់ហានិភ័យសុខភាព។

សំណល់វេជ្ជសាស្ត្រជាសមាសភាពមួយនៅក្នុងការគ្រប់គ្រងសំណល់រឹងហើយដែលមានបញ្ហាច្រើនជាងផ្នែកដទៃ។ ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅក្នុងរាជធានីភ្នំពេញនៅមានកំរិតទាបនៅឡើយដែលជាហេតុធ្វើឱ្យឥទ្ធិពលនៃសំណល់វេជ្ជសាស្ត្រអាចធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។ គេមិនអាចធ្វើការប៉ាន់ប្រមាណនូវចំនួនមនុស្សដែលបានរងគ្រោះដោយសារការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រមិនបានល្អបានឡើយ។ ចំនួនប៉ូលីគ្លីនិក និងគ្លីនិកនៅក្នុងរាជធានីភ្នំពេញមានការប្រែប្រួលជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការកើនឡើងនៃបរិមាណសំណល់វេជ្ជសាស្ត្រមានកំរិតខ្លាំងនៅក្នុងករណីណាដែលមានការកើនឡើងនៃអត្រាអ្នកជំងឺ។

ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រមិនប្រកបដោយលក្ខណៈត្រឹមត្រូវ នោះអាចធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសដល់កម្មករដែលទទួលបន្ទុកក្នុងការប្រមូល និងដឹកជញ្ជូន និងក្មេងអនាថាដើររើសសំរាម និងបរិស្ថាន។ តាមរបាយការណ៍បានគូសបញ្ជាក់ឱ្យឃើញថា មានប្រជាពលរដ្ឋក្រីក្រប្រមាណជា ២000 នាក់ (របាយការណ៍អង្កេតឆ្នាំ ២00២ របស់ក្រសួងបរិស្ថាន) កំពុងប្រកបរបរចិញ្ចឹមជីវិតតាមរយៈការដើរប្រមូលសំរាមនៅទីលានស្ទឹងមានជ័យ។ ពួកគេទាំងនោះអាចទទួល រងរបួសដោយផ្ទាល់ពីការមុតជាមួយនឹងម្ជុលចាក់ថ្នាំដែលសំបូរទៅដោយជំងឺគ្រប់ប្រភេទ។ ជំងឺថ្លើមប្រភេទ បេ និងសេ និងជំងឺអេដស៍ ដែលជាប្រភេទជំងឺដែលកំពុងមានការរីករាលដាលយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ដោយយល់ឃើញថា ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅទីក្រុងភ្នំពេញមានសភាពមិនល្អប្រសើរទើបវិទ្យាស្ថាន Blacksmith បានជួយឧបត្ថម្ភដល់ក្រសួងបរិស្ថាន តាមរយៈការិយាល័យគ្រប់គ្រងសំណល់រឹង និងសារធាតុប្រកបដោយគ្រោះថ្នាក់ ក្នុងគោលបំណងធ្វើការសិក្សាស្រាវជ្រាវ

លើបញ្ហានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដើម្បីកំណត់កាត់បន្ថយ និងទប់ស្កាត់នូវគ្រោះថ្នាក់ទាំងឡាយដែលកើតមានឡើងដល់សុខភាពសាធារណៈ និងបរិស្ថាន ។

**គោលបំណង**

រាល់សំណល់ពីសេវាថែទាំសុខភាពទាំងអស់ដែលបានមកពីគ្រប់មូលដ្ឋានថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជានឹងត្រូវ បានចាត់ចែង និងគ្រប់គ្រងដើម្បីធានាថា សំណល់ទាំងឡាយនោះនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សុខមាលភាពមនុស្ស និងបរិស្ថានឡើយ ។

**គោលដៅ**

១-ធ្វើឱ្យប្រាកដថា គ្រប់សំណល់ដែលបានមកពីសេវាថែទាំសុខភាព នៅក្នុងប្រទេសទាំងអស់ ត្រូវបានគ្រប់គ្រងត្រឹមត្រូវៈ បានញែកចេញពីគ្នា. បានទុកដាក់. បានប្រមូល បានដឹកជញ្ជូន បានសម្លាប់មេរោគ និងបានបោះចោលក្នុងលក្ខណៈសុវត្ថិភាព និងដោយលក្ខណៈបរិស្ថានល្អ ។

២-រៀបចំយុទ្ធសាស្ត្រដើម្បីកាត់បន្ថយនូវបរិមាណសំណល់ និងគ្រោះថ្នាក់ទាំងឡាយដែលបណ្តាលមកពីសំណល់សេវាថែទាំសុខភាព ។

៣-លុបបំបាត់ចោលការប្រើសមាសធាតុពុល. សមាសធាតុគ្រោះថ្នាក់ជាថែដន្យ (ដូចជាបារ៉ត) នៅក្នុងមូលដ្ឋានសុខាភិបាល ។

៤-អនុវត្តនូវបច្ចេកវិជ្ជាប្រព្រឹត្តិកម្មសំណល់ពីសេវាថែទាំសុខភាពទៅតាមពិធីសារអន្តរជាតិ សន្ធិសញ្ញា អនុសញ្ញាដូចជាអនុសញ្ញាក្រុងបាសែលស្តីពីសំណល់គ្រោះថ្នាក់ថែដន្យ ពិធីសារក្រុងក្យូតូ និងអនុសញ្ញាស្តុកខូមស្តីពីភាពកខ្វក់ទាំងឡាយនៃសរីរាង្គមិនបំបែកធាតុស្ថិតនៅយូរក្នុងបរិស្ថាន ។

៥-រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការទាំងអស់នៅតាមមូលដ្ឋានថែទាំសុខភាព និងអភិបាលជាប្រចាំ

៦-បង្កើត និងដាក់ឱ្យអនុវត្តនូវកម្មវិធីប្រាស្រ័យទាក់ទង អប់រំ និងផ្តល់ព័ត៌មាន ដល់សាធារណជនស្តីពីសារសំខាន់នៃការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពឱ្យបានត្រឹមត្រូវ ។

៧-ធានាថា ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព គឺអនុលោមទៅតាមផែនការដែលមានស្រាប់សម្រាប់ការងារ គ្រប់គ្រងសំណល់រឹងរបស់ទីក្រុង នៅក្នុងប្រទេស ។ ៕

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**